# រឿង ក្រពើ និងអ្នករទេះ

---

មានសត្វក្រពើមួយអាស្រ័យនៅក្នុងបឹងធំ លុះដល់រដូវប្រាំងទឹកបឹងនោះក៏រីងស្ងួតអស់ ក្រពើនោះនៅពុំបាន ទើបវារឡើងលើគោក ដើរត្រេចរកទីមានទឹក ។

កាលនោះមានតាចាស់ម្នាក់ បររទេះមក បានជួបនឹងក្រពើកំពុងវារនៅកណ្តាលផ្លូវ ។

ឯក្រពើក៏សុំដោយសាររទេះតានោះ តាសួរថា " ចៅឯងទៅណាដែរ ? ក្រពើប្រាប់ថា " ខ្ញុំនេះរកទីអាស្រ័យគ្មានទេ គឺបឹងដែលខ្ញុំធ្លាប់រស់នៅនោះ ឥឡូវទឹករីងស្ងួតអស់ នឹងនៅតទៅពុំបាន ទើបខ្ញុំខំស្វែងរកបឹង ស្ទឹង ទន្លេ ឯណាដែលមានទឹកនឹងអាស្រ័យនៅ បើតាមេត្តាសូមនាំខ្ញុំទៅឲ្យបានដល់ទីណាដែលមានទឹក ហើយដាក់ខ្ញុំត្រង់ទីនោះចុះ" ។ តានោះក៏ព្រមទើបដោះគោចេញពីនឹម ហើយលើកក្រពើឡើង ដាក់សណ្តូកលើទូករទេះ ហើយដោយក្រពើមិនទុកចិត្តខ្លួនក្រែងធ្លាក់ទើបប្រើឲ្យតានោះយកខ្សែមកចងខ្លួនភ្ជាប់នឹងទូករទេះ តាក៏ធ្វើតាមពាក្យក្រពើ ស្រេចហើយតាក៏ទឹមគោបរចេញទៅ លុះដល់ទីបឹង ១ មានទឹកតាក៏បញ្ឈប់រទេះដោះគោចេញ ហើយស្រាយចំណងក្រពើ ប្រាប់ថា " បឹងនេះមានទឹកគួរហើយ ចូរចៅលូនទៅនៅបឹងនេះចុះ"

ឯក្រពើជាសត្វអកតញ្ញូមិនដឹងគុណគេ ថែមទាំងឃ្លានអាហារ ដោយអត់មកយូរថ្ងៃហើយ ក៏និយាយទៅ ថា " តាឯងនេះចងយើងភ្ជាប់ នឹងទូករទេះ យើងបានសេចក្តីទុក្ខវេទនាពន់ពេកណាស់ តាឯងត្រូវឲ្យគោយើង ១ ស៊ី ទើបតាឯងរួចទោស , បើមិនឲ្យគោដល់យើងទេ ត្រូវយើងស៊ីតាឯងក្នុងពេលឥឡូវនេះ " ។

តានោះលុះឮក្រពើពោលពាក្យដូច្នោះ ក៏ភិតភ័យណាស់ ទើបស្តីអង្វរថា " នៃក្រពើ ! ខ្ញុំឯងនេះមានគុណ បានដឹកនាំបាឯងមកដល់ទីនេះ ឥឡូវបាចង់ស៊ីខ្ញុំវិញ ការនេះខ្ញុំឯងឥតទោសសោះ មិនគួរអ្នកនឹងពិឃាដ បើដូច្នេះ ខ្ញុំមិនសុខចិត្តទេ ចាំខ្ញុំទៅរកលោកចៅក្រម ឲ្យលោកជួយវិនិច្ឆ័យរឿងយើងនេះសិន សឹមប្រតិបត្តិតាមទៅ " ។ ក្រពើក៏ព្រមថា " អើតាឯងទៅរកចៅក្រមណាក៏ទៅឲ្យឆាប់ចុះ យើងចាំតាឯងនៅទីនេះ " ។

តានោះបានចេកទុំ ១ ស្និត ក៏កាន់ដើរទៅរកចៅក្រម ។ ទៅជួបនឹងសត្វទន្សាយគល់មួយ នៅលើដំបូក ទន្សាយក្រឡេកឃើញតាកាន់ចេកដើរកាត់ព្រៃចូលមកក៏សួរទៅថា " តាអើយតា តាឯងមាននេត្រាជលជោរសោកសៅ តើមានទោសទុក្ខយ៉ាងណា ចូរមកនេះសិន ? "

តាក៏និយាយរឿងខ្លួន នឹងក្រពើដែលកើតហេតុនឹងគ្នាប្រាប់ទន្សាយនោះសព្វប្រការ ។

ទន្សាយបានស្តាប់ដូច្នោះក៏ថា "អើអាសត្វក្រពើនោះជាសត្វមិនដឹងគុណតាឯង បើដូច្នេះខ្ញុំនឹងទទួលធ្វើជាចៅក្រមជម្រះឲ្យ តាកុំភ័យ ឲ្យតែចេកនេះមកខ្ញុំស៊ីសិន សឹមទៅជាមួយគ្នា " ។

តានោះក៏ឲ្យចេក ១ ស្និតទៅទន្សាយ ១ បរិភោគចេកអស់ហើយក៏នាំគ្នាទៅកាន់ដំណាក់ដែលឈប់នោះ ដល់ហើយទន្សាយនិយាយទៅថា " ម៉េចចៅក្រពើ ចៅឯងវង្វេងផ្លូវព្រៃ មិនដឹងជាទៅឯណាបានជាតាគាត់មេត្តាឲ្យដោយសារមកផង ឥឡូវបានដល់ទីសមគួរនឹងអាស្រ័យនៅហើយ ម្តេចចៅគិតរេរឃ្មើសគុណគាត់នឹងស៊ីគាត់វិញដូច្នោះ តើគាត់ធ្វើទុក្ខទោសអ្វីដល់ចៅឯង ?"។

ក្រពើក៏ឆ្លើយថា " អើលោកសុភា តានេះគាត់ឲ្យខ្ញុំដោយ សារមកនោះក៏មែន ប៉ុន្តែគាត់ធ្វើបាបខ្ញុំខ្លាំងណាស់ គឺគាត់ចងខ្ញុំភ្ជាប់ទៅនឹងទូករទេះខ្លាំងពេក រកតែរើខ្លួនដកដង្ហើមក៏ពុំបាន គាត់ធ្វើទុក្ខខ្ញុំយ៉ាងនេះ បានជាខ្ញុំខឹង គាត់ត្រូវតែប្រគល់គោគាត់បានមួយ មកឲ្យខ្ញុំស៊ី បើគាត់ពុំព្រមឲ្យគោនោះទេ ខ្ញុំត្រូវស៊ីគាត់វិញ " ។

ទន្សាយឆ្លើយអនុលោមតាមថា " អើតា ! តាឯងចងគេតឹងខ្លាំងហួស បានជាគេខឹង ចុះតាឯងម្តេចក៏ចងគ្នាតឹងខ្លាំងម្ល៉េះ គ្នារកតែរើខ្លួនមិនបានរួច ដូច្នោះ តា ? " ។

តានោះថា: ទេ ! ខ្ញុំបាទមិនបានចងតឹងទេលោក ចងល្មមតែជាប់ពុំឲ្យធ្លាក់ប៉ុណ្ណោះឯង ។

ទន្សាយថា: " អើ ! ខាងចោទក៏ថា ចងតឹងខ្លាំង ខាងចម្លើយថា ចងល្មម ពាក្យអ្នកទាំង ២ នាក់នេះ សឹងពុំមានអ្នកណាជាកសិណទេ បើដូច្នោះ ត្រូវចៅក្រពើឯង លូនឡើងមកលើទូករទេះវិញ ឲ្យតាគាត់ចងម្តងទៀត យើងនឹងមើលឲ្យដឹងថា តឹង ឬ ធូរ ទើបនឹងកាត់សេចក្តីនេះឲ្យយុត្តិធម៌ទៅបាន " ។

ឯក្រពើជាសត្វខ្លៅ ក៏វារឡើងទៅក្រាបលើទូករទេះ ឲ្យតានោះចងដូចមុន តាយកចំណងមកចងដូចមុនវិញ ទន្សាយសួរថា: ម្តេចចៅកុម្ភា, តាគាត់ចងតឹងយ៉ាងនេះឬ ? ក្រពើឆ្លើយថា ! " ទេ លោក ! កាលគាត់ចងខ្ញុំមុននោះតឹងលើសនេះខ្លាំងណាស់ បើចងប៉ុណ្ណេះ ខ្ញុំទៅខឹងអ្វីនឹងគាត់"។ ទន្សាយថា "អើ ចូរតារឹតទ្វេឡើងទៀតឲ្យបានសុខចិត្ត "។ តានោះក៏រឹតចំណងឡើងទៀត។ ទន្សាយសួរថា " ម្តេច ! ចៅកុម្ភា ម្តងនេះតើតឹងដូចកាលជាន់មុននោះហើយ ឬនៅ ? " ។ ក្រពើថា "នៅ ! ពុំទាន់ស្មើចងមុននោះទេ " ។ ទន្សាយបង្គាប់ថា " តាឯងកាប់ឈើមកធ្វើជាកូនកំព្រារឹតម្តងទៀតទៅ " តានោះក៏ធ្វើតាម ហើយតាំងត្របែងរឹតទាំងមុខទាំងក្រោយអស់ទំហំដៃ ។ ឯក្រពើនោះត្រូវគេត្របែងដោយកូនកំព្រាខ្លាំង តឹងខ្លួនស្ទើរតែដកដង្ហើមចេញពុំបាន ទើបឆ្លើយថា "សូមទានកាលជាន់មុននោះ គាត់ចងតឹងយ៉ាងនេះឯង, លោកអើយ នរណាឡើយនឹងអត់បាន សូមលោកជាសាក្សីមើលចុះ តើអ្នកឯណាខុសឯណាត្រូវ " ។

ទន្សាយឃើញក្រពើរើខ្លួនពុំរួចហើយ ទើបបង្គាប់តានោះថា " តាចាំអ្វីទៀត ពូថៅធំក្នុងរទេះនោះមិនយកមកពុះក្បាលវាទៅ ទុកឲ្យវារស់ធ្វើអ្វី ខ្មោចអាសត្វអកតញ្ញូ ពុំដឹងគុណគេ ដែលធ្វើគុណខ្លួន " ។ តាចាស់នោះបានឱកាសដោយទន្សាយប្រាប់ដូច្នោះ ក៏ស្ទុះទៅយកពូថៅធំមក សំពងកាប់ក្រពើនោះ កាត់ជាកំណាត់តូចធំ ក្រពើក៏លុះនូវក្តីអន្តរាយជីវិតហោង ។

សុភាទន្សាយបង្គាប់ថា "កងកន្ទុយវានោះ តាឯងឆ្អើរដាក់យកទៅស្ងោរពិសាឬញាំក៏បាន ឯពោះវៀនបត់ចន្ទាសវានោះញាំភ្លាជាការប្រសើរណាស់តាអើយ " ។

ឯតានោះ ធ្វើតាមសុភាទន្សាយប្រាប់សព្វប្រការ ហើយយកចេកត្រសក់ជូនទន្សាយដោយខ្លួនបានផុតអំពីអន្តរាយស្រេចហើយយកគោមកទឹមរទេះ លាសុភាទន្សាយបរទៅកាន់ទីឋាននៃអាត្មាហោង ។